*រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៤*

# សេចក្តីសំរេចលេខ ១១៨ សសរ.

## ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី ទទួលបន្ទុក គ.ជ.នា

**សំរេច**

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី ជំនួសឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រីទទួលបន្ទុក គ.ជ.នា ដែលត្រូវអញ្ជើញទៅបំពេញ បេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៤ រហូតដល់ថ្ងៃ ឯកឧត្តម គាត ឈន់ វិលត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមដែលមានឈ្មោះ ក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |